ភ្នំពេញ, ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៣

## ២ . សារាចរ

## សារាចរលេខ ១៦ សរ.

រាជរដ្ឋាភិបាលកម្ពុជា

សូមទូលថ្វាយ និង ជំរាបមក

- ព្រះអង្គម្ចាស់ ឯកឧត្តម រដ្ឋមន្ត្រីគ្រប់ក្រសួង
- លោក អភិបាលគ្រប់ខេត្ត ក្រុង

**កម្មវត្ថុ** : អំពីការឈប់សំរាកការងារក្នុងឱកាសបុណ្យជាតិ និងបុណ្យប្រពៃណីជាតិ ។

ក្នុងគោលបំណងចូលរួមអបអរសាទរក្នុងឱកាសបុណ្យជាតិ និង បុណ្យប្រពៃណីជាតិនៅចុងឆ្នាំ ១៩៩៣ នេះ រាជរដ្ឋាភិបាលកម្ពុជាសំរេចអនុញ្ញាតអោយមន្ត្រី រាជការ គ្រប់ក្រសួង- ស្ថាប័នអង្គភាព និង ខេត្ត- ក្រុង ទូទាំងព្រះរាជាណាចក្រកម្ពុជា ឈប់សំរាកការងារ តាមកាលបរិច្ឆេទ ដូចខាងក្រោម ÷

១- បុណ្យចំរើនព្រះជន្មវស្សាព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ក្នុង គំរប់ខួប ៧១ យាងចូល ៧២ ព្រះវស្សា ត្រូវបានឈប់សំរាកការងារចំនួន ០៣ ថ្ងៃ គឺថ្ងៃទី ៣០- ៣១ ខែ តុលា និង ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ។

២- បុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា ត្រូវបានឈប់សំរាកការងារចំនួន ០២ ថ្ងៃ គឺថ្ងៃទី ៨ និង ៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ។

៣- បុណ្យអុំទូក-អកអំបុក សំពះព្រះខែ ត្រូវបានឈប់សំរាកការងារចំនួន ០៣ ថ្ងៃ គឺថ្ងៃទី ២៧- ២៨ និង ២៩ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ។

ការកំណត់ឈប់សំរាកការងារក្នុងឱកាសបុណ្យជាតិ និង បុណ្យប្រពៃណីជាតិសំរាប់ឆ្នាំ ១៩៩៤ និង ត្រូវជូនដំណឹងនៅពេលក្រោយទៀត ។

ទទួលបានសារាចរនេះ សូមព្រះអង្គម្ចាស់ ឯកឧត្តម និង អស់ លោកជ្រាប ។

ជ. រាជរដ្ឋាភិបាលកម្ពុជា

**ឧបនាយករដ្ឋមន្ត្រី**

ហត្ថលេខា និង ត្រា

**គាត ឈន់**